# ការស្ទង់លទ្ធផលគ្រួសារ

សួស្តីលោកអ្នកឪពុកម្តាយជាទីមេត្រី

សូមអរគុណលោកអ្នកដែលស្ម័គ្រចិត្តជួយបំពេញ *ការស្ទង់លទ្ធផលគ្រួសារ* នៃរដ្ឋមីនេសូតា។ ចម្លើយរបស់លោកអ្នកនឹងត្រូវទុកជាសម្ងាត់ និងមិនត្រូវចែកចាយទៅសមាជិកនៃក្រុម ISFP ឡើយ។ រួមបញ្ចូលជាមួយនឹងចម្លើយរបស់គ្រួសារឯទៀត ចម្លើយរបស់លោកអ្នកនឹងត្រូវប្រើដើម្បីពង្រឹងកម្មវិធីអន្តរាគមន៍នៅក្នុងសហគមន៍របស់លោកអ្នក។ ចម្លើយទាំងអស់ពីគ្រួសារនានានៅក្នុងរដ្ឋមីនេសូតា នឹងត្រូវបញ្ចូលគ្នា និងត្រូវរាយការទៅក្រសួងសិក្សាធិការជាតិ ទុកជាសេចក្តីបញ្ជាក់អំពីគុណភាពនៃប្រព័ន្ធអន្តរាគមន៍បឋមនៅក្នុងរដ្ឋទាំងមូល។

លោកម៉ាទី ស្មិត នៃក្រសួងសិក្សាធិការរដ្ឋមីនេសូតា

**សេចក្តីណែនាំ:**

នៅក្នុងទំព័របន្តបន្ទាប់ខាងមុខ សូមគូសរង្វង់ជុំវិញលេខ ដែលត្រូវចំជាងគេ ចំពោះគ្រួសាររបស់លោកអ្នក នៅក្នុងបច្ចុប្បន្នកាលនេះ។ បើសិនជាសេចក្តីថ្លែងណាមួយ ត្រូវជិតចំ តែស្ទើរបន្តិច នោះសូមគូសរង្វង់ជុំវិញលេខដែលក្រោមមួយលេខបន្ទាប់។ ឧទាហរណ៍ បើសេចក្តីថ្លែងនៅលេខ៣ ជិតត្រូវតែស្ទើរបន្តិច នោះត្រូវគូសរង្វង់លេខ២។

លោកអ្នកនឹងកត់សំគាល់ថា ចម្លើយរបស់លោកអ្នកមានពាក្យថា "យើងខ្ញុំ"។ ពាក្យថាយើងខ្ញុំនេះ សំដៅចំពោះគ្រួសារលោកអ្នក។ មិនជាការអ្វីទេ បើសិនជាលោកអ្នកឆ្លើយសំរាប់លោកអ្នកផ្ទាល់ខ្លួន (មតិរបស់លោកអ្នក ឬក៏បទពិសោធន៍របស់លោកអ្នក) ឬក៏ឆ្លើយក្នុងនាមជាមតិរួម ឬបទពិសោធន៍រួមក្នុងគ្រួសារ។

សូមដាក់ការស្ទង់នេះដែលបំពេញរួចហើយនោះ នៅក្នុងស្រោមសំបុត្រដែលមានភ្ជាប់មកជាមួយនេះ រួចផ្ញើទៅអាស័យដ្ឋានដូចមាននៅខាងក្រោមនេះ:

*Early Intervention Program, Family Outcomes Survey*
*Minnesota Department of Education*
*1500 Highway 36 West*
*Roseville, MN  55113*

**© 2005 SRI International.** Version: 12-16-05.

បង្កើតឡើងដោយមណ្ឌលលទ្ធផលនៃបឋមកុមារ ដោយមានការគាំទ្រពីការិយាល័យកម្មវិធីសិក្សាពិសេសនៃក្រសួងសិក្សាធិការជាតិ

# ការស្ទង់លទ្ធផលគ្រួសារ

## ការយល់ដឹងអំពីគុណភាព សមត្ថភាព និងសេចក្តីត្រូវការពិសេស របស់កូនលោកអ្នក

១. កូនរបស់លោកអ្នកនៅកំពុងតែចំរើនឡើង និងរៀនចេះដឹងឡើង។ តើលោកអ្នកយល់ពីការលូតចំរើនទៅមុខរបស់កូនលោកអ្នក បានត្រឹមកំរិតណា ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំទើបតែចាប់ផ្តើមយល់ពីការចំរើនឡើងរបស់កូនយើងខ្ញុំ | | យើងខ្ញុំយល់ជាទូទៅពីការចំរើនឡើងរបស់កូនយើងខ្ញុំ តែយើងខ្ញុំត្រូវការចេះដឹងច្រើនបន្ថែមទៀត | | យើងខ្ញុំមានការយល់ដឹងច្រើនគ្រាន់បើអំពីការចំរើនឡើងរបស់កូនយើងខ្ញុំ | | យើងខ្ញុំមានការចេះដឹងច្បាស់លាស់អំពីការចំរើនឡើងរបស់កូនយើងខ្ញុំ |

២. កូនក្មេងខ្លះមានសេចក្តីត្រូវការខាងផ្នែកសុខភាពពិសេសខុសគេ ពិការ ឬចំរើនឡើងយឺតខុសធម្មតា។ តើលោកអ្នកយល់ដឹងដល់កំរិតណាអំពីសេចក្តីត្រូវការពិសេសរបស់កូនលោកអ្នក?

សូមគូសនៅត្រង់នេះ ប្រសិនបើកូនរបស់លោកអ្នកគ្មានសេចក្តីត្រូវការអ្វីពិសេស រួចហើយរំលងទៅឆ្លើយសំណួរទី៣

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅក្នុងពេលនេះ យើងខ្ញុំមិនដឹងអ្វីច្រើនទេ | | យើងខ្ញុំយល់ដឹងខ្លះៗ ក៏ប៉ុន្តែ នៅមានសំណួរជាច្រើនទៀតដែលគ្មានចម្លើយ | | យើងខ្ញុំដឹងច្រើន ប៉ុន្តែ នៅត្រូវការឬចង់ដឹងបន្ថែមទៀត | | យើងខ្ញុំជឿទុកចិត្តថា យើងខ្ញុំដឹងយល់ស្ទើរតែទាំងអស់នៅក្នុងពេលនេះ |

៣. វិជ្ជាជីវិនដែលធ្វើការជាមួយលោកអ្នកនិងកូនរបស់លោកអ្នក ចង់ដឹងថា តើកិច្ចការដែលគេធ្វើនោះ មានដំណើរការល្អ ឬយ៉ាងណា។ តើលោកអ្នកអាចនឹងដឹងថាកូនរបស់លោកអ្នកបានលូតចំរើនទៅមុខឬទេ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅក្នុងពេលនេះ យើងខ្ញុំមិនអាចនឹងសន្និដ្ឋានថាកូនរបស់យើងខ្ញុំបានលូតចំរើនទៅមុខទេ | | ពេលខ្លះ យើងខ្ញុំដឹងថាកូនរបស់យើងខ្ញុំបានលូតចំរើនទៅមុខ។ យើងខ្ញុំនៅត្រូវការរៀនច្រើនទៀត | | ធម្មតា យើងខ្ញុំអាចនឹងដឹងបាន កាលណាកូនរបស់យើងខ្ញុំបានចំរើនទៅមុខ | | យើងខ្ញុំអាចនឹងដឹងបានជានិច្ច កាលណាកូនរបស់យើងខ្ញុំបានចំរើនទៅមុខ |

| Office Use Only<br>MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|

# ការស្ទង់លទ្ធផលគ្រួសារ

## ស្គាល់សិទ្ធិរបស់លោកអ្នក និង គាំទ្រកូនរបស់លោកអ្នក

៤. មានកម្មវិធី និងសេវកិច្ចផ្សេងៗ ដែលកូន និងគ្រួសាររបស់លោកអ្នកអាចប្រើបាន។ តើលោកអ្នកដឹងទេ ថាអ្វីខ្លះទៅ ដែលមានផ្តល់សំរាប់កូន និងគ្រួសាររបស់លោកអ្នក?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំទើបតែនឹងចាប់ផ្តើមដឹងអំពីកម្មវិធី និងសេវកិច្ច ដែលគេផ្តល់ | | យើងខ្ញុំដឹងអំពីកម្មវិធី និងសេវកិច្ចខ្លះ តែនៅមានការច្រើនទៀតដែលត្រូវរៀន | | យើងខ្ញុំគិតថា យើងខ្ញុំដឹងអំពីកម្មវិធី និងសេវកិច្ចភាគច្រើន | | យើងខ្ញុំដឹងច្បាស់ល្អ អំពីកម្មវិធី និង សេវកិច្ច ដែលគេផ្តល់ |

៥. ឳពុកម្តាយជួបជាមួយវិជ្ជាជីវិនជាញឹកញាប់ ដើម្បីគ្រោងសេវកិច្ច និងសកម្មភាពផ្សេងៗ។ តើលោកអ្នកស្រួលចិត្តគំនិតទេ ក្នុងការចូលរួមប្រជុំទាំងនេះជាមួយគេ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅពេលនេះ យើងខ្ញុំមានការពិបាកណាស់ ក្នុងការចូលប្រជុំទាំងនេះ | | យើងខ្ញុំមិនសូវជាស្រួលចិត្តគំនិតទេ ក្នុងការចូលប្រជុំ ប៉ុន្តែយើងខ្ញុំនៅតែទៅ | | យើងខ្ញុំគ្មានការពិបាកអ្វីទេ ក្នុងការចូលប្រជុំ | | យើងខ្ញុំស្រួលនឹងចូលប្រជុំណាស់ |

៦. គ្រួសាររបស់ក្មេងដែលមានសេចក្តីត្រូវការពិសេស មានសិទ្ធិ ទាំងមានការដែលគ្រួសារនោះអាចធ្វើបាន បើសិនជាគេមិនពេញចិត្ត។ តើលោកអ្នកស្គាល់សិទ្ធិរបស់លោកអ្នកត្រឹមកំរិតណា ហើយតើលោកអ្នកធ្វើអ្វីទៅ បើសិនជាលោកអ្នកមិនពេញចិត្ត?

សូមគូសនៅត្រង់នេះ បើសិនជាកូនរបស់លោកអ្នកគ្មានសេចក្តីត្រូវការពិសេស រួចហើយរំលងទៅសំណួរទី៧

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំមិនដឹងច្បាស់លាស់ទេ អំពីសិទ្ធិរបស់យើងខ្ញុំ ឬអំពីអ្វីដែលត្រូវធ្វើ បើសិនជាយើងខ្ញុំមិនពេញចិត្ត | | យើងខ្ញុំយល់អំពីសិទ្ធិទូទៅរបស់យើងខ្ញុំ ប៉ុន្តែមិនច្បាស់អំពីច្រកណាដែលធ្វើបាន បើសិនជាយើងខ្ញុំមិនពេញចិត្ត | | យើងខ្ញុំគិតថា យើងខ្ញុំស្គាល់សិទ្ធិរបស់ខ្លួន និងដឹងថាអ្វីដែលត្រូវធ្វើបាន បើសិនជាយើងខ្ញុំមិនពេញចិត្ត | | យើងខ្ញុំស្គាល់សិទ្ធិរបស់ខ្លួនច្បាស់ និងដឹងច្បាស់ថាអ្វីដែលត្រូវធ្វើ បើសិនជាយើងខ្ញុំមិនពេញចិត្ត |

| Office Use Only<br>MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|

# *ការស្ទង់លទ្ធផលគ្រួសារ*

## ជួយកូនរបស់លោកអ្នកឲ្យលូតចំរើន និងរៀនសូត្រ

៧. ឳពុកម្តាយទាំងអស់តែងតែជួយកូនរបស់ខ្លួនឲ្យលូតចំរើននិងរៀនសូត្រ ប៉ុន្តែ ពេលខ្លះ វាពិបាកនឹងដឹងថាត្រូវធ្វើអ្វីខ្លះ។ តើលោកអ្នកអាចនឹងពណ៌នាបានទេ អំពីសមត្ថភាពរបស់ខ្លួនក្នុងការជួយកូនឲ្យលូតចំរើននិងរៀនសូត្រ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំត្រូវការដឹងច្រើនទៀត អំពីរបៀបជួយកូនឲ្យលូតចំរើននិងរៀនសូត្រ | | យើងខ្ញុំដឹងជាគោល។អំពីរបៀបជួយកូនឲ្យលូតចំរើននិងរៀនសូត្រ តែនៅមានសំណួរច្រើនទៀត | | យើងខ្ញុំដឹងច្រើនអំពីរបៀបជួយកូនឲ្យលូតចំរើននិងរៀនសូត្រ | | យើងខ្ញុំដឹងច្បាស់ណាស់ អំពីរបៀបជួយកូនឲ្យលូតចំរើននិងរៀនសូត្រ |

៨. ឳពុកម្តាយទាំងអស់ព្យាយាមជួយកូនរបស់ខ្លួនរៀនចេះឲ្យមានកិរិយាមាយាទតាមគន្លងដែលខ្លួនប៉ងប្រាថ្នា ប៉ុន្តែ ពេលខ្លះ វាពិបាកនឹងដឹងថាត្រូវធ្វើអ្វីខ្លះ។ តើលោកអ្នកអាចពណ៌នា អំពីសមត្ថភាពរបស់ខ្លួន ក្នុងការជួយកូនរៀនឲ្យមានកិរិយាមាយាទតាមគន្លងដែលខ្លួនប៉ងប្រាថ្នា?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំត្រូវការដឹងច្រើនទៀត ពីរបៀបដែលជួយកូន ឲ្យមានកិរិយាមាយាទតាមបំណងរបស់ខ្លួន | | យើងខ្ញុំដឹងជាគោល។ ពីរបៀបដែលជួយកូនឲ្យមានកិរិយាល្អតែនៅមានសំណួរច្រើនទៀត | | យើងខ្ញុំដឹងថាខ្លួនចេះរបៀបដែលជួយកូនឲ្យមានកិរិយាមាយាទល្អ | | យើងខ្ញុំដឹងថាខ្លួនចេះច្បាស់ណាស់ ពីរបៀបដែលជួយកូនឲ្យមានកិរិយាមាយាទល្អ |

៩. គ្រួសាររបស់លោកអ្នកបានធ្វើការជាមួយវិជ្ជាជីវិន ដើម្បីបង្កើតផែនការសំរាប់ជួយកូនរបស់លោកអ្នក ឲ្យរៀនចេះដឹងជំនាញការថ្មី និងកិរិយាមាយាទថ្មី។ តើលោកអ្នកអាចនឹងជួយកូនរបស់ខ្លួនឲ្យរៀនចេះដឹង ឬអនុវត្តជំនាញការទាំងនេះ នៅផ្ទះឬនៅក្នុងសហគមន៍ បានដល់កំរិតណា?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំមិនទាន់បានចាប់ផ្តើមជួយកូនឲ្យរៀនចេះដឹងជំនាញការនិងកិរិយាមាយាទទាំងនេះទេ | | យើងខ្ញុំបានចាប់ផ្តើមជួយកូនឲ្យរៀនចេះដឹងជំនាញការនិងកិរិយាមាយាទទាំងនេះហើយ | | យើងខ្ញុំជួយកូនឲ្យរៀន និងអនុវត្ត ជំនាញការនិងកិរិយាទាំងនេះញឹកញាប់ តែមិនទាន់បានទៀងទាត់ដូចប្រាថ្នាទេ | | យើងខ្ញុំជួយកូនឲ្យរៀន និងអនុវត្ត ជំនាញការនិងកិរិយាមាយាទទាំងនេះយ៉ាងទៀងទាត់គ្រប់ពេលវេលា |

| Office Use Only MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|

# ការស្ទង់លទ្ធផលគ្រួសារ

## វត្តមាននៃប្រព័ន្ធគាំទ្រ

១០. មនុស្សជាច្រើនមានមនោសញ្ចេតនាថា កាលណាបានសន្ទនាជាមួយមនុស្សម្នាក់ទៀត នឹងជួយគេឲ្យដោះស្រាយបញ្ហា ឬចូលរួមសប្បាយកាលណាមានការល្អកើតឡើង។ តើគ្រួសាររបស់លោកអ្នក មានអ្នកណាដែលលោកអ្នកទុកចិត្តថាគេស្តាប់ និងសាសងជាមួយបានឬទេ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅពេលនេះ យើងខ្ញុំគ្មានអ្នកណាមួយ ដែលយើងខ្ញុំអាចសាសងជាមួយ អំពីអ្វីៗដែលកើតឡើងក្នុងជីវិតរបស់យើងខ្ញុំទេ | | យើងខ្ញុំប្រហែលជាអាចនឹងរកអ្នកណាបានយ៉ាងតិចម្នាក់ ដែលយើងខ្ញុំអាចនឹងសាសងជាមួយបាន តែយើងខ្ញុំមិនសូវជាពេញចិត្តនឹងស្ថានការនេះទេ | | ធម្មតា យើងខ្ញុំមានអ្នកឯទៀត ដែលយើងខ្ញុំអាចសាសងជាមួយបាន ពីការផ្សេងៗ | | ប្រាកដណាស់ថាមានមនុស្សនៅក្នុងជីវិតរបស់យើងខ្ញុំ ដែលយើងខ្ញុំអាចនឹងសន្ទនាពិភាក្សាជាមួយបាន នៅពេលណាដែលដែលយើងខ្ញុំត្រូវការ |

១១. គ្រួសារទាំងឡាយ ពេលខ្លះត្រូវតែពឹងផ្អែកលើអ្នកឯទៀត ដើម្បីជួយនៅពេលត្រូវការ ឧទាហរណ៍ដូចជា ផ្តល់ជំនិះ ទៅផ្សារទិញឥវ៉ាន់ ឬជួយមើលកូនម្តងម្កាល។ តើលោកអ្នកមានអ្នកណាដែលលោកអ្នកអាចពឹងពាក់ នៅពេលមានសេចក្តីត្រូវការឬទេ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅពេលនេះ គ្រួសារយើងខ្ញុំ គ្មានអ្នកណាដែលយើងខ្ញុំអាចពឹងពាក់បាន នៅពេលមានសេចក្តីត្រូវការទេ | | នៅពេលមានអាសន្ន យើងខ្ញុំមានអ្នកដែលយើងខ្ញុំអាចពឹងពាក់បាន ប៉ុន្តែមិនមែនសំរាប់ការទូទៅរាល់ថ្ងៃទេ | | តាមធម្មតា មានអ្នកដែលយើងខ្ញុំពឹងពាក់បាន កាលណាយើងខ្ញុំមានសេចក្តីត្រូវការ | | យើងខ្ញុំស្ទើរតែមានអ្នកដែលយើងខ្ញុំអាចពឹងពាក់បានជានិច្ច កាលណាយើងខ្ញុំមានសេចក្តីត្រូវការ |

១២. គ្រួសារភាគច្រើនមានអ្វីៗដែលគេចូលចិត្តធ្វើ។ តើគ្រួសារលោកអ្នកមានលទ្ធភាពនឹងធ្វើអ្វីៗដែលលោកអ្នកចូលចិត្តធ្វើនោះបានឬទេ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| នៅពេលនេះ វាជាការពិបាកណាស់នឹងធ្វើអ្វីៗដែលយើងខ្ញុំចូលចិត្តធ្វើ | | យើងខ្ញុំអាចចូលរួមធ្វើអ្វីៗខ្លះៗ ដែលយើងខ្ញុំចូលចិត្តធ្វើ តែមិនបានច្រើនតាមចំណូលចិត្តទេ | | យើងខ្ញុំអាចចូលរួមធ្វើអ្វីៗជាច្រើនដែលយើងខ្ញុំចូលចិត្តធ្វើ | | យើងខ្ញុំអាចចូលរួមធ្វើអ្វីៗស្ទើរតែទាំងអស់ ដែលយើងខ្ញុំចូលចិត្តធ្វើ |

| Office Use Only<br>MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|

# ការស្ទង់លទ្ធផលគ្រួសារ

## ការប្រើអង្គការដែលមាននៅក្នុងសហគមន៍របស់ខ្លួន

១៣. ក្មេងទាំងអស់សុទ្ធតែត្រូវការពេទ្យថែរក្សាសុខភាព។ តើលោកអ្នកអាចពណ៌នាអំពីពេទ្យថែរក្សាសុខភាពរបស់កូនលោកអ្នកយ៉ាងណាខ្លះ?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំគ្មានពេទ្យថែរក្សាសុខភាព សំរាប់កូនរបស់យើងខ្ញុំ ដែលយើងខ្ញុំចង់បាននោះទេ | | យើងខ្ញុំមានពេទ្យថែរក្សាសុខភាពកូនខ្វះ តែយើងខ្ញុំមានសេចក្តីត្រូវការច្រើនទៀត ទើបត្រូវតាមបំណងចិត្ត | | យើងខ្ញុំមានពេទ្យថែរក្សាសុខភាព សំរាប់កូនល្អល្មម | | យើងខ្ញុំមានពេទ្យថែរក្សាសុខភាព សំរាប់កូនដ៏ល្អប្រសើរ |

១៤. គ្រួសារជាច្រើនត្រូវការការមើលក្មេងដែលមានគុណភាពល្អ។ នេះមិនមែននិយាយពីការមើលក្មេងម្តងម្កាលនោះទេ តែគឺជាការមើលក្មេងដោយទៀងទាត់ ពេញមួយថ្ងៃឬពាក់កណ្តាលថ្ងៃ។ តើលោកអ្នកអាចពណ៌នាអំពីការមើលក្មេងដែលលោកអ្នកបានទទួលនោះ យ៉ាងណាខ្លះនៅបច្ចុប្បន្នកាលនេះ?

សូមគូសសនៅត្រង់នេះ បើសិនជាលោកអ្នកមិនចង់បានការមើលក្មេង រួចហើយរំលងទៅសំណួរលេខ១៥

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| យើងខ្ញុំគ្មានការមើលក្មេងដែលយើងខ្ញុំប៉ងទេ ឬដោយសារកូនរបស់យើងខ្ញុំមានសេចក្តីត្រូវការពិសេស យើងខ្ញុំបានសំរេចថាមិនរកការមើលក្មេងទេ | | យើងខ្ញុំមានការមើលក្មេង ប៉ុន្តែ មានការខ្វះខាតច្រើនទៀត មុននឹងបានដូចចំណង់របស់យើងខ្ញុំ | | យើងខ្ញុំមានការមើលក្មេងល្អសមរម្យ សំរាប់កូន | | យើងខ្ញុំមានការមើលក្មេងល្អប្រសើរ សំរាប់កូន |

១៥. គ្រួសារជាច្រើនចង់ឲ្យកូនរបស់ខ្លួនលេងជាមួយកូនក្មេងឯទៀត ឬចូលរួមក្នុងសកម្មភាពសាសនា សហគមន៍ ឬសង្គម។ តើលោកអ្នកអាចពណ៌នាពីការចូលរួមរបស់កូនក្នុងសកម្មភាពទាំងនេះយ៉ាងណាខ្លះ?

សូមគូសសនៅត្រង់នេះ បើសិនជាលោកអ្នកមិនចង់ឲ្យកូនរបស់ខ្លួនចូលរួមក្នុងសកម្មភាពប្រភេទនេះ រួមហើយរំលងទៅសំណួរទី១៦

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| កូនរបស់យើងខ្ញុំមិនចូលរួមក្នុងសកម្មភាពនេះទេ ឬដោយសារកូនរបស់យើងខ្ញុំមានសេចក្តីត្រូវការពិសេស យើងខ្ញុំបានសំរេចមិនរកការទាំងនេះ | | កូនរបស់យើងខ្ញុំចូលរួមក្នុងសកម្មភាពសង្គមនិងសហគមន៍ខ្លះៗ ប៉ុន្តែ ទាល់តែមានលើសនេះច្រើនទៀត ទើបត្រូវតាមចំណង់យើងខ្ញុំ | | កូនរបស់យើងខ្ញុំចូលរួមក្នុងសកម្មភាពសង្គមនិងសហគមន៍ច្រើនល្មម | | កូនរបស់យើងខ្ញុំចូលរួមក្នុងសកម្មភាពសង្គមនិងសហគមន៍ក្នុងកំរិតដ៏ប្រសើរ |

| Office Use Only MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|

# ការស្ទង់លទ្ធផលគ្រួសារ

## មនោសញ្ចេតនារបស់លោកអ្នកចំពោះអន្តរាគមន៍បឋម

១៦. តើអន្តរាគមន៍បឋមបានជួយគ្រួសាររបស់លោកអ្នកឲ្យដឹងនិងយល់អំពីសិទ្ធិទាំងឡាយរបស់ខ្លួនបានត្រឹមកំរិតណា?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| អន្តរាគមន៍បឋមមិនបានជួយយើងខ្ញុំឲ្យដឹងអំពីសិទ្ធិរបស់ខ្លួនទេ | | អន្តរាគមន៍បឋមបានជួយខ្លះៗឲ្យយើងខ្ញុំដឹងអំពីសិទ្ធិរបស់ខ្លួន | | អន្តរាគមន៍បឋមបានផ្តល់ជំនួយល្អ ឲ្យយើងខ្ញុំបានដឹងអំពីសិទ្ធិរបស់គ្រួសារខ្លួន | | អន្តរាគមន៍បឋមបានផ្តល់ជំនួយដ៏ល្អប្រសើរ ឲ្យយើងខ្ញុំបានដឹងអំពីសិទ្ធិរបស់គ្រួសារខ្លួន |

១៧. តើអន្តរាគមន៍បឋមបានជួយគ្រួសាររបស់លោកអ្នកឲ្យចេះទាក់ទងប្រាប់គេដោយស័ក្តសិទ្ធិអំពីសេចក្តីត្រូវការទាំងឡាយរបស់កូនលោកអ្នក បានត្រឹមកំរិតណា?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| អន្តរាគមន៍បឋមមិនបានជួយគ្រួសាររបស់យើងខ្ញុំឲ្យចេះទាក់ទងដោយស័ក្តសិទ្ធិអំពីសេចក្តីត្រូវការរបស់កូនទេ | | អន្តរាគមន៍បឋមបានជួយគ្រួសាររបស់យើងខ្ញុំខ្លះៗ ឲ្យចេះទាក់ទងដោយស័ក្តសិទ្ធិអំពីសេចក្តីត្រូវការរបស់កូន | | អន្តរាគមន៍បឋមបានជួយគ្រួសាររបស់យើងខ្ញុំយ៉ាងល្អ ឲ្យចេះទាក់ទងដោយស័ក្តសិទ្ធិអំពីសេចក្តីត្រូវការរបស់កូន | | អន្តរាគមន៍បឋមបានជួយគ្រួសារយើងខ្ញុំយ៉ាងល្អប្រសើរឲ្យចេះទាក់ទងដោយស័ក្តសិទ្ធិអំពីសេចក្តីត្រូវការរបស់កូន |

១៨. តើអន្តរាគមន៍បឋមបានជួយគ្រួសាររបស់លោកអ្នកឲ្យមានសមត្ថភាពក្នុងការជួយកូនរបស់លោកអ្នកឲ្យលូតចំរើននិងរៀនសូត្រ បានត្រឹមកំរិតណា?

| 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|
| អន្តរាគមន៍បឋមមិនបានជួយគ្រួសាររបស់យើងខ្ញុំឲ្យមានសមត្ថភាពក្នុងការជួយកូនឲ្យលូតចំរើននិងរៀនសូត្រទេ | | អន្តរាគមន៍បឋមបានជួយគ្រួសាររបស់យើងខ្ញុំខ្លះៗ ឲ្យចេះជួយកូនឲ្យលូតចំរើន និងរៀនសូត្រ | | អន្តរាគមន៍បឋមបានជួយគ្រួសាររបស់យើងខ្ញុំជាច្រើន ក្នុងការជួយកូនឲ្យលូតចំរើន និងរៀនសូត្រ | | អន្តរាគមន៍បឋមបានជួយគ្រួសាររបស់យើងខ្ញុំយ៉ាងល្អប្រសើរ ក្នុងការជួយកូនឲ្យលូតចំរើន និងរៀនសូត្រ |

| Office Use Only MARSS Number: | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|